# កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩




## យើងរួមគ្នាបន្តអភិវឌ្ឍ

## ១.គោលដៅ

គោលដៅនៃកម្មវិធីជាតិ គឺដើម្បី :

- អភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួម និង មានសមធម៌
- លើកកម្ពស់បរិមាណ គុណភាព និងការទទួលបានសេវា សាធារណៈឱ្យមានភាពប្រសើរឡើង និង
- រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

## ២.គោលបំណង :

គោលបំណងនៃកម្មវិធីជាតិគឺដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផ្អែកតាម គោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យដែលធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាពសំដៅលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋព្រមទាំងរួមចំណែក ក្នុងការកាត់បន្ថយ ភាពក្រីក្រនៅតាមមូលដ្ឋាននីមួយៗ ។

## ៣.សមាសធាតុកម្មវិធី

សមាសធាតុនៃកម្មវិធីជាតិមានចំនួន ០៥ គឺ :

- **សមាសធាតុកម្មវិធីទី១ "ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ" :** សមាសធាតុកម្មវិធីទី១មានគោលបំណងដើម្បី បង្កើត ស្ថាប័នរដ្ឋបាលថ្នាក់ក្រោម ជាតិ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងមួយតាមគោលការណ៍ នៃ ការចូលរួមតាមបែបប្រជាធិបតេយ្យ ដែលមាននីតិវិធីប្រតិបត្តិការ របៀបរបបគ្រប់គ្រងជាប្រព័ន្ធមួយ ដែល ឆ្លើយតបនឹងខ្សែគណនេយ្យភាពថ្មី សម្រាប់ធានាឱ្យមាន អភិបាលកិច្ចប្រកបដោយតម្លាភាព និងមានគណនេយ្យភាព សំដៅធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព ។
- **សមាសធាតុកម្មវិធីទី២ "ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស" :** សមាសធាតុកម្មវិធីទី២មាន គោលបំណងដើម្បីរៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកប ដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា ។

- **សមាសធាតុកម្មវិធីទី៣ "ការផ្ទេរមុខងារ"** : សមាសធាតុ កម្មវិធីទី៣ មានគោលបំណង ដើម្បីលើកកម្ពស់បរិមាណ និង គុណភាពសេវាសាធារណៈ តាមរយៈការផ្ទេរមុខងារឱ្យទៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាន ដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារ ទាំងនោះ។



- **សមាសធាតុកម្មវិធីទី៤ "ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ"** : សមាសធាតុ កម្មវិធីទី៤ មានគោលបំណងបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ មួយរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលនោះ មានលទ្ធភាពកៀរគរ និងទទួលបានធនធានគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចក្នុងការ គ្រប់គ្រង និងបែងចែក ធនធានទាំងនោះប្រកបដោយ គណនេយ្យភាព និង តម្លាភាព។
- **សមាសធាតុកម្មវិធីទី៥ "ស្ថាប័នគាំទ្រកំណែទម្រង់និមជ្ឈការ និងវិសហមជ្ឈការ"** : សមាសធាតុកម្មវិធីទី៥មានគោល បំណង ដើម្បីពង្រឹងស្ថាប័នថ្នាក់ជាតិនានា សម្រាប់ដឹកនាំ ការអនុវត្តកម្មវិធី ជាតិរយៈពេល១០ឆ្នាំ និងគាំទ្រដល់ រដ្ឋបាលថ្នាក់ក្រោមជាតិ។

**រៀបចំដោយ**
លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់
ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
ខែកក្កដា ឆ្នាំ២០១០

បញ្ជាក់ : ប្រធានបទចំនួនបីដែលមានលក្ខណៈអន្តរវិស័យ គឺ ការបញ្ជ្រាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងគណនេយ្យភាព ត្រូវបានដាក់បញ្ចូលទៅក្នុងសមាស-ធាតុកម្មវិធីទាំង៥ ។

## ៤.ដំណាក់កាលនៃការអនុវត្តកម្មវិធីជាតិ

ការអនុវត្តកម្មវិធីជាតិមានបីដំណាក់កាល ដូចខាងក្រោម :

- **ដំណាក់កាលទី១ "២០១០-២០១២"**:ក្នុងដំណាក់កាលនេះគឺ ត្រូវបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ចទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ និងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ ដែល ផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- **ដំណាក់កាលទី២ "២០១៣-២០១៥"** : ក្នុងដំណាក់កាល នេះគឺត្រូវពង្រឹង និងពង្រីករចនាសម្ព័ន្ធ និងប្រព័ន្ធដើម្បីធានា ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពដាក់ចេញ និងអនុវត្ត នូវគោលនយោបាយសម្រាប់មូលដ្ឋានខ្លួន សំដៅលើកកម្ពស់ ការផ្តល់សេវាសាធារណៈ និងបង្កើនលទ្ធភាពទទួលយកសេវា សាធារណៈរបស់ស្ត្រី និងអ្នកដែលបានទទួលសេវាសាធារណៈ ជាមូលដ្ឋានតិចតួច ។
- **ដំណាក់កាលទី៣ "២០១៦-២០១៩"** : ក្នុងដំណាក់កាល នេះគឺត្រូវកែតម្រូវកម្មវិធីនានា និងធ្វើឱ្យមានឥទ្ធិពលកាន់តែ ស៊ីជម្រៅ តាមរយៈការអនុវត្តមេរៀន និងបទពិសោធន៍ដែល ទទួលបាន និងធានាថាកម្មវិធីនានាស្តីពីការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្លើយតប និងឆ្លុះបញ្ចាំង ពីគោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗរបស់រាជរដ្ឋាភិបាល ។

នៅចុងបញ្ចប់នៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ ចរិតលក្ខណៈ និងវិសាលភាព នៃសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមាន ការផ្លាស់ប្តូរយ៉ាងច្រើនហើយទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយមន្ទីរ អង្គភាពក៏នឹងមានការផ្លាស់ប្តូរផងដែរ ។



**៥.ការគ្រប់គ្រងកម្មវិធីជាតិ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) គឺជាស្ថាប័នទទួលខុសត្រូវក្នុងការ សម្របសម្រួល និងអនុវត្តកម្មវិធីជាតិ។ ដូច្នេះ គ.ជ.អ.ប ត្រូវពិនិត្យ ពិភាក្សា និងអនុម័តក្នុងការដាក់បញ្ចូលនូវរាល់សកម្មភាពទាំងអស់នៃកម្មវិធីជាតិដែលបានគ្រោងឡើងនៅដំណាក់កាលទាំងបីទៅក្នុង ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ថ្វីត្បិតតែកម្មវិធីជាតិនេះជាកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលក៏ដោយក៏ប៉ុន្តែការអនុវត្តកម្មវិធីនេះទាមទារឱ្យមាននូវធនធាននិងការគាំទ្រពីរាជរដ្ឋាភិបាល និងពីសំណាក់ដៃគូអភិវឌ្ឍន៍ នានាផងដែរ។

ជាមួយគ្នានេះដើម្បីធានាឱ្យការអនុវត្តកម្មវិធីជាតិឆ្លើយតបទៅនឹងគោលដៅនិងគោលបំណងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពគ.ជ.អ.បនឹងរៀបចំប្រព័ន្ធ និងយន្តការនៃការអភិវឌ្ឍន៍សមត្ថភាព ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃព្រមទាំងការធ្វើសវនកម្ម ជាចាំបាច់ផងដែរ។